ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣១២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការអនុវត្តអាករលើតម្លៃបន្ថែម
## លើការនាំចូល និងការផ្គត់ផ្គង់ ទំនិញមួយចំនួន

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
- បានឃើញប្រកាសលេខ ៣០៣ សហវ.ពដ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១
- យោងតាមការសម្រេចក្នុងវេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជនលើកទី១៧ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៤ ដែលជាការប្រជុំគណៈរដ្ឋមន្ត្រីបើកទូលាយ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**សម្រេច ៖**

## ប្រការ ១ .- គោលបំណង

ប្រកាសនេះមានគោលបំណង សម្រួលយន្តការអាករលើតម្លៃបន្ថែម ដើម្បីលើកកំពស់សកម្មភាពកសិកម្មដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ២ .- ការអនុគ្រោះនូវអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ

អាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនដូចខាងក្រោមនេះ ត្រូវបានរដ្ឋទទួលបន្ទុក ៖

១- ជីគ្រប់ប្រភេទ រួមមាន ជីសំរាប់ប្រើក្នុងវិស័យកសិកម្មលើគ្រប់មុខដំណាំដែលផ្សំដោយជាតិគីមី ជាតិសរីរាង្គ និងរ៉ែធម្មជាតិ។

២- ពូជដំណាំគ្រប់ប្រភេទ រួមមាន ៖

ក- គ្រាប់ពូជដំណាំគ្រប់ប្រភេទ

ខ- បំណែកពូជដំណាំគ្រប់ប្រភេទប្រើសំរាប់ការដាំដុះជា ដើម មើម ខ្នែង មែកសាក មែកផ្សាំ វល្លិ ។ល។

៣- បសុឱសថ រួមមាន ឱសថគ្រប់ប្រភេទប្រើប្រាស់តែលើសត្វគ្រប់ប្រភេទ សំរាប់ការទ្រទ្រង់សុខភាព ព្យាបាល ការពារ និងបង្កើនផលិតភាពរបស់សត្វ។

៤- ចំណីសត្វ និងចំណីបន្ថែម រួមមាន ៖

ក- ចំណីសត្វគ្រប់ប្រភេទសំរាប់ការទ្រទ្រង់ការលូតលាស់របស់សរីរាង្គសត្វ

ខ- ចំណីបន្ថែមគ្រប់ប្រភេទ វីតាមីន ឬអង្គធាតុរ៉ែផ្សេងៗទៀត សំរាប់ប្រើប្រាស់បន្ថែមលើចំណីសត្វ

គ- អង្កាម កន្ទក់ និងកម្ទេចចុងអង្ករ សម្រាប់ធ្វើចំណីសត្វ។

៥- ពូជសត្វគ្រប់ប្រភេទ រួមមាន ៖

ក- ពូជសត្វស្រុកគ្រប់ប្រភេទ

ខ- ពូជសត្វព្រៃគ្រប់ប្រភេទ ។

៦- គ្រឿងយន្ត និងឧបករណ៍កសិកម្មប្រភេទ ៖

ក- គោយន្តភ្ជួរ រាស់ និងបន្លាស់សំរាប់គ្រឿសារ

ខ- ម៉ាស៊ីនកិនចំណីសត្វ

គ- ឧបករណ៍បណ្ដុះគ្រាប់ពូជ ឬភ្ញាស់ស៊ុតសត្វ

ឃ- ក្បាលបូមទឹកនៃម៉ាស៊ីនបូមទឹក ។

## ប្រការ ៣ .- ការកត់ត្រាចំណូលចំណាយ

អាករលើតម្លៃបន្ថែមលើទំនិញដូចមានចែងក្នុងប្រការ ២ ខាងលើ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាបូកសរុបជាចំណូលនៃថវិកាប្រចាំខែ ហើយត្រូវបានកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ "ជំពូក៣០"។

**ប្រការ ៤.-**

ប្រកាសលេខ ៣០៣ សហវ.ពដ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូលនិងការផ្គត់ផ្គង់ទំនិញមួយចំនួន ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ